# មូលនិធិកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាផ្តល់
# កម្ចីឥណទានខ្នាតតូចដល់ប្រជាជននៅខេត្តកែប

នៅព្រឹកថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១០ នៅទីតាំងសមាគមនារីខេត្តកែប មានរៀបចំពិធីផ្តល់កម្ចី ឥណទានខ្នាតតូចដល់ប្រជាពលរដ្ឋក្នុងខេត្តកែប ចំនួន១១១ គ្រួសារ ដោយ**មូលនិធិកាត់បន្ថយភាពក្រីក្ររបស់ ប្រជាជនកម្ពុជា** ហៅកាត់ថា: **PAL** ក្រោមអធិបតីភាពឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានមូលនិធិកាត់បន្ថយភាពក្រីក្រ របស់ប្រជាជនកម្ពុជា ដោយមានការចូលរួម ពីឯកឧត្តម លោកជំទាវ ជាតំណាងរាស្ត្រខេត្តកែប អភិបាល អភិបាលរងខេត្ត សមជិកក្រុមប្រឹក្សាខេត្ត ក្រុង ខណ្ឌ ស្រុក និងតំណាងមន្ទីរអង្គភាពជុំវិញខេត្ត និងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ ។






លោកជំទាវ **ជិន សុធីម** សមាជិការក្រុមប្រឹក្សាខេត្តនិងជាប្រធានគណកម្មការសមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍ខេត្តកែប បានមានប្រសាសន៍ ស្វាគមន៍ និងថ្លែងអំណរគុណដល់មូលនិធិកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ដែលមានឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ជាប្រធានដែលបានយកចិត្តទុកដាក់ជាសំខាន់ទៅ លើបងប្អូននារី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ជាមេគ្រួសារ និងជាអ្នកពាក់ព័ន្ធដោយផ្ទាល់ ជាមួយនិងអាជីវកម្មខ្នាតតូច ដើម្បីចំណូល និងលើកកំពស់ជីភាពគ្រួសារ ។

មានប្រសាសន៍សំណេះសំណាលនាឱកាសនោះឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** និងជាប្រធានមូលនិធិ PAL បានលើកឡើងពីប្រវត្តិនៃមូលនិធិ PAL ដែលបានចាប់កំណើតចាប់តាំងពីឆ្នាំ ១៩៩៨ ដោយ គំនិតផ្តួចផ្តើម ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចបានឈរជាប្រធានកិត្តិយស នៃមូលនិធិ PAL នេះក្នុងគោលដៅជួយប្រជាពលរដ្ឋក្រីក្រឱ្យមានលទ្ធភាពបង្កើតមុខរបរ និងស្វែងរកប្រភពចំណូលក្នុងគ្រួសារ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា: ដើមទុនរបស់មូលនិធិ ប្រមាណ ៦ ម៉ឺន ដុល្លាសហរដ្ឋអាមេរិក គឺបានដោយសារការប្រគុំតន្ត្រី សប្បុរសធម៌ នៅពហុកីឡដ្ឋានអូឡាំពិក កាលពីឆ្នាំ ១៩៩៩ ។ ចាប់ពីពេលនោះមក មូលនិធិ PAL បានធ្វើប្រតិបត្តិការរបស់ខ្លួន នៅតាមបណ្តាខេត្តជាច្រើន រួមទាំងខេត្តកែបនេះផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ប្រធានមូលនិធិ PAL បានឯកភាព ចំពោះសំណូមពររបស់ខេត្ត ដែលស្នើឱ្យមន្ត្រីរាជការមានលទ្ធភាពខ្ចីឥណទានខ្នាតតូចនេះ ដោយឯកឧត្តមបានបញ្ជាក់ថា: ប្រជាពលរដ្ឋគ្រប់រូបអាចមកដាក់ពាក្យស្នើសុំ ដើម្បីខ្ចីមូលនិធិនេះបាន បើសិនជាពួកគាត់ពិតជាមានគោលដៅច្បាស់លាស់ ក្នុងការគេចផុតពីភាពក្រីក្រ ។ ឯកឧត្តម បានដាស់តឿនដល់ប្រជាពលរដ្ឋទាំងអស់ ក្រោយពីទទួលបានឥណទាននេះហើយ ត្រូវប្រើប្រាស់ឥណទាននេះឱ្យចំគោលដៅ និងមានប្រសិទ្ធិភាព ពីព្រោះថា: នៅខេត្តកែប ជាខេត្តទេសចរណ៍មួយ ដែលប្រជាពលរដ្ឋមានលទ្ធភាពច្រើនសំរាប់អាជីវកម្មខ្នាតតូចរបស់ខ្លួន ដូចជាការចិញ្ចឹមសត្វ-ការដាំដុះ-ការលក់ដូរគ្រឿងហូបចុកសំរាប់ភ្ញៀវទេសចរណ៍ និងមុខរបរជាងជួសជុល ទោចក្រយានយន្តជាដើម ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានប្រគល់ថវិការដល់ប្រជាពលរដ្ឋ ចំនួន១១១ គ្រួសារដែលក្នុងមួយគ្រួសារទទួលឥណទានខ្នាតតូចនេះ ចំនួន ៨0ម៉ឺនរៀល ដោយគិតការប្រាក់ ចំនួន១% ក្នុងមួយខែ ហើយត្រូវសងមកមូលនិធិវិញ ក្នុងរយៈពេល0១ឆ្នាំ បន្ទាប់ ។

យោងតាមសំណូពរ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** នឹងឧបត្ថម្ភម៉ាស៊ីន កំព្យូទ័រ មួយកំប្លេ និងសំភារៈការិយាល័យ មួយចំនួន ដល់សមាគមនារីខេត្ត សំរាប់បំរើការងារប្រចាំថ្ងៃ ។

ដោយឡែកនៅព្រឹកថ្ងៃដដែលនោះដែរ នៅឯស្នងការនគរបាលខេត្តកែប ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានឧបត្ថម្ភថវិកាចំនួន**៥០០០ដុល្លាសហរដ្ឋអាមេរិក** ដល់ឯកឧត្តម **ហាស់ សារ៉េត** អភិបាលនៃគណៈអភិបាលខេត្តកែប សំរាប់កែលំអរផ្លូវឡើង ចង្កេះភ្នំ សំរាប់សំរួលការធ្វើដំណើរនៃភ្ញៀវទេសចរណ៍ ព្រមទាំងបានប្រគល់ជូន ម៉ាស៊ីនកំព្យូទ័រមួយកំប្លេ ម៉ាស៊ីនផលិតកាត០១គ្រឿង និង ម៉ាស៊ីនថត ឌីជីថល០១គ្រឿង ដល់ស្នងការ នគរបាលខេត្តកែប ដើម្បីដំណើរ ការធ្វើអត្តសញ្ញាណប័ណ្ណ ជូនប្រជាពលរដ្ឋឱ្យមានភាពរលូន ។